ទំនុកដំកើង៣៩-៤១

# ជំពូក ៣៩

*ជាទចនា ទំនុកសម្រាប់ពេលបញ្ចុះសព*

គម្ពីរទំនុកដំកើងជំពូក១៩ បរិយាយពីភាពទ័លច្រក ភាពទន់ខ្សោយ និងភាពប្រចុជូនរបស់មនុស្សលោកគ្រប់រូប។ មនុស្សលោកកើតមករស់នៅ ហើយស្លាប់ទៅវិញ។ គម្ពីរទំនុកដំកើងជំពូក៣៩ ច្រើនគេយកមកប្រើក្នុងពេលបញ្ចុះសព។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ គម្ពីរទំនុកដំកើងនេះមានខ្លឹមសារ មិនមែនសម្រាប់តែអ្នកស្លាប់ប៉ុណ្ណោះទេ គឺមានដល់ជីវិតរបស់យើងគ្រប់ៗគ្នាដែរ។ ជំពូកនេះ បរិយាយពីភាពទ័លច្រក ភាពទន់ខ្សោយ ដែលមនុស្សមានបាបគ្រប់រូបជួបប្រទះនៅក្នុងជីវិត។ មនុស្សលោកជាមាបនភាវៈមួយប្រភេទ ដែលទទួលបរាជ័យជាងគេទាំងអស់ក្នុងចំណោមមាបនវត្ថុនានា ដែលព្រះជាម្ចាស់បង្កើតមក។ មនុស្សលោកទទួលបរាជ័យទាំងស្រុងផ្នែកវិញ្ញាណចក្រ។ វិញ្ញាណចក្រជាទំនាក់ទំនងរវាងមនុស្សជាតិផ្ទាល់ជាមួយនឹងព្រះជាម្ចាស់។ ព្រះជាម្ចាស់បង្កើតមនុស្សលោកមកអោយមានការទទួលខុសត្រូវខ្ពស់នៅចំពោះព្រះអង្គ តែផ្ទុយទៅវិញ មនុស្សបានផ្តាច់ស្ពានទំនាក់ទំនងជាមួយនឹងព្រះអង្គ រួចហើយជ្រើសរើសយកអំពើបាបវិញ។ ដោយសារខ្វះទំនាក់ទំនងជាមួយព្រះជាម្ចាស់នេះហើយ បានជាជីវិតមនុស្សបែរទៅជាគ្មានន័យទៅវិញ។ ជីវិតគ្មានន័យ ពីព្រោះកើតមក

រស់នៅទ្រទម្ងន់នៃជីវិត រួចហើយស្លាប់ទៅវិញ។ ដរាបណាមិនមានព្រះរាជបុត្រាគង់ជាមួយ ជីវិតរស់នៅគ្មានទិសដៅអ្វីអោយបានពិតប្រាកដ។ ម្យ៉ាងវិញទៀត គម្ពីរទំនុកដំកើងជំពូក៣៩ ជាទំនុកនៃស្តេចដាវីឌដែលទ្រង់លើកសម្រាប់លោកយេឌូថិនជាមេភ្លេង។ ព្រះបាទដាវីឌ តែងច្រៀងសរសើរតម្កើងព្រះអង្គ ដែលមានលោកយេឌូថិន លោកអេសាប និងលោកហ៊ីមានជាអ្នកនាំមុខក្រុមភ្លេង។

សូមយើងពិចារណានូវពាក្យពេជន៍ និងខ្លឹមសារដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅនៅក្នុងគម្ពីរទំនុកដំកើងជំពូក៣៩នេះ ដូចតទៅ។

> **ខ្ញុំបាននឹកថា ខ្ញុំនឹងប្រយ័តផ្លូវខ្លួន ដើម្បីមិនឱ្យអណ្តាតខ្ញុំធ្វើបាបឡើយ ខ្ញុំនឹងដាក់បង្ហៀទប់មាត់ខ្ញុំ ក្នុងកាលដែលពួកអាក្រក់ នៅចំពោះមុខ (ទំនុកដំកើង៣៩:១)។**

ព្រះបាទដាវីឌចូលចិត្តប្រើមាត់លោក ដើម្បីច្រៀងសរសើរតម្កើងព្រះជាម្ចាស់ជាជាងប្រើអណ្តាតនិយាយជាមួយនឹងមនុស្សដែលគ្រប់គ្នាមានអាយុខ្លី។

> **ខ្ញុំបាននៅជាគ ឥតនិយាយអ្វីសោះ គឺបាននៅស្ងៀមចំពោះទាំងសេចក្តីល្អផង នោះសេចក្តីទុក្ខព្រួយរបស់ខ្ញុំក៏ជ្រួលឡើង (ទំនុកដំកើង៣៩:២)។**

ព្រះបាទដាវីឌ មិនចង់និយាយរឿងអ្វីផ្សេងជាមួយនឹងមនុស្សលោកធម្មតាទេ។ បើលោកចង់និយាយវិញ លោកចង់និយាយតែពីទឹកចិត្តរបស់លោក នៅចំពោះវត្តមានរបស់ព្រះជាម្ចាស់។

**ចិត្តខ្ញុំបានក្តៅនៅក្នុងខ្លួន កំពុងដែលខ្ញុំគិតរំពឹង នោះភ្លើងក៏ឆួលឡើង ហើយអណ្តាតខ្ញុំបាននិយាយថា (ទំនុកដំកើង ៣៩:៣)។**

ពេលនេះ ព្រះបាទដាវីឌមានបន្ទូលទៅកាន់ព្រះអម្ចាស់ផ្ទាល់។

**ឱព្រះយេហូវ៉ាអើយ សូមឱ្យទូលបង្គំដឹងពីចុងបំផុតនៃទូលបង្គំ ហើយពីចំនួនថ្ងៃអាយុនៃទូលបង្គំផង ដើម្បីឱ្យទូលបង្គំបានដឹងជាមានជីវិតស្រួយអម្បាលម៉ានទៅ (ទំនុកដំកើង៣៩:៤)។**

ព្រះបាទដាវីឌពិចារណាជីវិតរបស់លោក រួចហើយយល់ឃើញថា ជីវិតរបស់មនុស្សមានភាពទ័លច្រកគ្រប់អន្លើ។ ស្តេចអង្គនេះដណ្តឹងសួរថា "តើជីវិតរស់នៅមានខ្លឹមសារអ្វី?" បច្ចុប្បន្ននៅក្នុងចំណោមយុវជន យុវនារី គេតែងសួរសំណួរខាងលើនេះដែរ។ បន្ទាប់ពីប្រជាពលរដ្ឋខ្មែរ យើងឆ្លងកាត់គ្រាលំបាកទូទៅទាំងប្រទេស យើងចង់រស់នៅដោយសុខសាន្តមានស្រែភ្លឺ មានផ្ទះសម្បែង មានផ្លាំងបាយតួច មានការរស់នៅ

ដោយសុខដុមរមនា។ ពលរដ្ឋខ្មែរគ្រប់រូប មិនចង់ដឹងរឿងអ្វីផ្សេងក្រៅពីសេចក្តីសុខផ្ទាល់ខ្លួនឡើយ។ ប៉ុន្តែ អស់រយៈពេលជាច្រើនឆ្នាំមកហើយ មកទល់ពេលនេះ យើងមិនបានឃើញមានសេចក្តីសុខដូចយើងប្រាថ្នានោះកើតឡើងដល់យើងទេ។ អសន្តិសុខក្នុងសង្គម ភាពអនីតិរដ្ឋគ្រប់បែបយ៉ាង ការទាស់ទែងប្រជែងអំណាចគ្នា នៅតែមានភាពស្រស់បំព្រងជានិច្ចនៅឡើយ។ មិនតែប៉ុណ្ណោះ ជីវិតពលរដ្ឋម្នាក់ៗរស់នៅក្នុងការភ័យខ្លាច ការគំរាមកំហែង ភាពច្របូកច្របល់ គ្មានសណ្តាប់ធ្នាប់នៅក្នុងសង្គម។ តើមនុស្សលោករស់នៅសម្រាប់ទទួលភាពអសន្តិសុខបែបនេះជានិច្ចរៀងរហូតឬ? តើអ្វីទៅដែលជាខ្លឹមសារពិតប្រាកដនៃជីវិត? ព្រះបាទដាវីឌសួរសំណួរដូចយើងសួរសព្វថ្ងៃនេះដែរ។

សេចក្តីដែលខ្ញុំរៀបរាប់ខាងលើជារឿងធម្មតា។ ការមិនស្គាល់ព្រះអម្ចាស់យេស៊ូវ ធ្វើអោយជីវិតគ្មានន័យពិតមែន។ ប៉ុន្តែ រឿងដែលរាប់ថាជាការអកុសលមួយទៀត គឺកូនរបស់ព្រះជាម្ចាស់ដែលកំពុងដើរជាមួយព្រះអង្គ ជួនកាលរាប់ជីវិតខ្លួនថាគ្មានន័យដែរ។ ខ្ញុំសូមដណ្តឹងសួរដល់គ្រីស្ទបរិស័ទដែលជាមាតាបិតា តើលោកអ្នករស់នៅដោយបង្ហាញអោយបុត្រធីតារបស់លោកអ្នក ស្គាល់ព្រះអម្ចាស់យេស៊ូវឬមួយក៏រស់នៅក្នុងជីវិតមួយ ដែលបិទមិនអោយកូនចៅចង់ស្គាល់ព្រះយេស៊ូវនៅក្នុងជីវិតរបស់ខ្លួន? តើព្រះអម្ចាស់យេស៊ូវជាសុភមង្គលសម្រាប់ជីវិតគ្រួសាររបស់លោកអ្នកដែរឬទេ? សូមលោកអ្នកកុំបន្លំភ្នែកកូនអោយសោះ កូនស្គាល់ថា លោកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវពិតប្រាកដ ឬមួយគ្រាន់តែជឿតែសំបកក្រៅ។ បើលោកអ្នកបន្សល់ទុកនូវផ្នត់គំនិតដែលជឿតែសំបកក្រៅ កូនរកកន្លែងកក់ក្តៅលើព្រះយេស៊ូវមិនឃើញទេ។

ព្រះបាទដាវីឌ បានចារទុកនូវគំនិតដែលមនុស្សលោកសព្វថ្ងៃនេះមានដែរ។ លោកមានប្រសាសន៍ថា "ឱព្រះយេហូវ៉ាអើយ សូមអោយទូលបង្គំដឹងពីចុងបំផុតនៃទូលបង្គំ ហើយពីចំនួន ថ្ងៃអាយុនៃទូលបង្គំផង"។ ត្រង់នេះ ព្រះបាទដាវីឌចង់មានបន្ទូលថា ព្រះជាម្ចាស់ជាអង្គដែលផ្តល់នូវមូលហេតុ និងខ្លឹមសារនៃជីវិតរបស់មនុស្សគ្រប់រូប។

**មើលទ្រង់បានធ្វើឱ្យថ្ងៃអាយុនៃទូលបង្គំបានខ្លី ប្រវែង១ចំអាមដៃ ហើយជំនួរជីវិតរបស់ទូលបង្គំ ដូចជាឥតមានសោះនៅចំពោះទ្រង់ មែនហើយ គ្រប់មនុស្ស នោះទាំងមនុស្សនៅក្នុងសណ្ឋានពេញវ័យ នោះក៏ឥតប្រយោជន៍ទទេដែរ។ -បង្អង់ (ទំនុកដំកើង ៣៩:៥)។**

ចុងខនេះមានពាក្យ "បង្អង់" ដែលមានន័យថា ឈប់ ឈរ ហើយឈាន។ សូមលោកអ្នកពិចារណាមើលពីធាតុពិតនៃជីវិតរបស់មនុស្សលោកចុះ។ ជីវិតរបស់មនុស្សលោកខ្លីផង ផុយផង។ មនុស្សលោកទទួលបរាជ័យទាំងស្រុងក្នុងវិស័យវិញ្ញាណចក្រ។ ដូច្នេះ ឈើបេង ឬឈើកកោះ មានជីវិតស្ថិតស្ថេរយូរអង្វែងជាងជីវិតមនុស្សលោក ដែលពឹងលើដង្ហើមចេញចូល។

**ប្រាកដមែន គ្រប់មនុស្សទាំងឡាយដើរ ប្រៀបដូចជាស្រមោល ទទេ គេជ្រួលជ្រើមឡើងជាឥតប្រយោជន៍ គេបង្គរទ្រព្យសម្បត្តិ ឡើង ឥតដឹងជាអ្នកណានឹងទទួលទេ (ទំនុកដំកើង៣៩:៦)។**

មែនហើយ! មនុស្សលោកប្រៀបឧបមាដូចជាស្រមោលតែប៉ុណ្ណោះ។ "គេបង្គរទ្រព្យសម្បត្តិឡើង ឥតដឹងជាអ្នកណានឹងទទួល" តើមានប្រយោជន៍អ្វីសម្រាប់ខ្លួន? គ្រីស្ទបរិស័ទខ្លះខំសន្សំសំចៃគ្រប់បែបយ៉ាង ដើម្បីបង្គរទ្រព្យសម្បត្តិទុកនៅលើផែនដី ធ្វើហាក់ដូចជាផែនដីនេះ ជាលំនៅស្ថានដ៏អស់កល្បជានិច្ចសម្រាប់ខ្លួន។ កូនចៅជំនាន់ក្រោយរបស់គេ កើតឡើងមិនស្គាល់ព្រះជាម្ចាស់។ គេចាយវាយទ្រព្យសម្បត្តិនោះអស់ទៅ។ ដោយសារឃើញមានហេតុការណ៍ជាក់ស្តែងបែបនេះកើតឡើង បានជាស្តេចដាវីឌដណ្តឹងសួរថា "តើអ្វីទៅជាអត្ថន័យសម្រាប់ជីវិត?"

**ឥឡូវនេះ ឱព្រះអម្ចាស់អើយ តើទូលបង្គំនៅរង់ចាំអ្វីទៀត ដ្បិតទូលបង្គំសង្ឃឹមដល់ទ្រង់តែ១ប៉ុណ្ណោះ (ទំនុកដំកើង៣៩:៧)។**

ចំណែកព្រះបាទដាវីឌ ទ្រង់សម្លឹងមើលព្រះជាម្ចាស់ រួចហើយមានបន្ទូលថា "ទូលបង្គំសង្ឃឹមដល់ទ្រង់តែ១ប៉ុណ្ណោះ"។ ដរាបណាលោកអ្នកមិនបែរមុខមករកព្រះជាម្ចាស់ សេចក្តីសង្ឃឹមរបស់លោកអ្នកក្នុងជីវិតនេះ គ្មានន័យអ្វីឡើយ។

**សូមជួយទូលបង្គំឱ្យរួចពីគ្រប់អំពើរំលងរបស់ទូលបង្គំ សូមកុំឱ្យទូលបង្គំបានជាទីដៀលត្មះរបស់ពួកមនុស្សឆោតល្ងង់ឡើយ (ទំនុកដំកើង៣៩:៨)។**

មិនតែប៉ុណ្ណោះ ព្រះបាទដាវីឌចង់រស់នៅធ្វើជាគំរូល្អដល់ពលរដ្ឋរបស់លោក។

**ទូលបង្គំបាននៅជាគ ឥតហើបមាត់សោះ ដ្បិតគឺជាទ្រង់ដែលបានធ្វើការនោះ (ទំនុកដំកើង៣៩:៩)។**

ព្រះបាទដាវីឌ មិនចង់សម្តែងគំនិតរបស់លោកអោយសាធារណៈជនដឹងទេ ពីព្រោះសាធារណៈជនមិនយល់ពីខ្លឹមសារនៃដំណើរ ដែលលោកដើរជាមួយនឹងព្រះជាម្ចាស់។

**សូមដករំពាត់របស់ទ្រង់ចេញពីទូលបង្គំ ទូលបង្គំត្រូវវិនាសហើយ ដោយសារព្រះហស្តទ្រង់វាយ (ទំនុកដំកើង៣៩:១០)។**

ទ្រង់យល់ថា ព្រះជាម្ចាស់ប្រៀនប្រដៅដល់លោកផ្ទាល់ ដើម្បីអោយលោកស្គាល់ខ្លឹមសារពិតនៃជីវិត។ មនុស្សលោកគ្រប់រូបចាំបាច់ត្រូវតម្រង់ខ្សែជីវិតរបស់ខ្លួន

អោយត្រូវតាមទិសដៅដែលព្រះជាម្ចាស់បង្កើតខ្លួនមក។ ចំណុចដៅចុងក្រោយបង្អស់នៃជីវិតរបស់មនុស្សលោក មិនមែនទីបច្ឆា ឬផ្នូរទេ។ ព្រលឹងរបស់មនុស្សលោកមិនត្រូវស្លាប់ មិនត្រូវកប់ មិនត្រូវគេដុត ពេលគេយករូបកាយយើងទៅរំលាយបន្ទាប់ពីយើងស្លាប់ហើយនោះក៏ទេដែរ។ ព្រលឹងរបស់មនុស្សមានផ្លូវវែងឆ្ងាយទៅមុខណាស់។ ឯផ្លូវវែងឆ្ងាយទៅមុខទៀត គឺជាជីវិតអស់កល្បជានិច្ច។ តើលោកអ្នកសង្ឃឹមថា ជីវិតអស់កល្បជានិច្ចរបស់លោកអ្នក មានភាពរុងរឿង ឬខ្មោងងឹត?

> **ឱព្រះយេហូវ៉ាអើយ សូមស្តាប់ពាក្យ ដែលទូលបង្គំអធិស្ឋាន សូមផ្ទៀងព្រះកាណ៌ស្តាប់សំរែកទូលបង្គំផង សូមទ្រង់កុំនៅធ្មឹងនឹងទឹកភ្នែកនៃទូលបង្គំឡើយ ដ្បិតទូលបង្គំជាអ្នកដទៃនៅចំពោះទ្រង់ជាអ្នកស្នាក់នៅ ដូចជាពួកឰយុកោទូលបង្គំទាំងអស់គ្នាដែរ (ទំនុកដំកើង៣៩:១២)។**

មនុស្សលោកគ្រប់រូបដែលធ្លាប់រស់នៅលើផែនដីនេះ គ្រាន់តែជាជនភៀសខ្លួនតែប៉ុណ្ណោះ។ មនុស្សលោកភាគច្រើនមិនបានជាគិតថា ខ្លួនជាជនភៀសខ្លួនស្នាក់នៅបណ្តោះអាសន្ននៅលើផែនដីនេះតែប៉ុណ្ណោះទេ។ មួយថ្ងៃៗ គេខំប្រឹងយកដៃខ្វាំដីយកជើងចាក់គ្រឹះនៅលើព្រះធរណីគិតថាផែនដីនេះ ជាកម្មសិទ្ធិរបស់ខ្លួនអស់កល្បជានិច្ច។ គេបង្កើតផាសុកភាពមិនគួរគប្បីសម្រាប់ជីវិតខ្លួន។ សូមជ្រាបចុះថា ព្រះគម្ពីរ

សម្តែងរួចហើយ មនុស្សលោកគ្រាន់តែជនភៀសខ្លួនរស់នៅបណ្តោះអាសន្នលើផែនដីរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ ព្រះជាម្ចាស់បង្កើតមនុស្សគ្រប់រូបមក អោយមានទិសដៅពិតប្រាកដសម្រាប់ជីវិត។ ឯទិសដៅពិតប្រាកដនោះគឺ ត្រូវទៅរស់នៅក្នុងទីក្រុងបរិសុទ្ធដែលព្រះជាម្ចាស់ជាអ្នកសង់ និងជាអ្នករក្សា "ហេព្រើរ១១:១០"។ សព្វថ្ងៃនេះ តើលោកអ្នកសង្ឃឹមដល់អ្វី? សូមលោកអ្នកសង្ឃឹមដល់ព្រះយេហូវ៉ាតែមួយអង្គប៉ុណ្ណោះចុះ!

**ឱសូមប្រណីដល់ទូលបង្គំ ដើម្បីឱ្យទូលបង្គំបានមានកំឡាំងឡើង មុនដែលទូលបង្គំចេញបាត់ទៅ ហើយមិនមានទៀត (ទំនុកដំកើង ៣៩:១៣)។**

មុននឹងលាចាកពីលោកយើងនេះទៅ ចូរយើងតាំងចិត្តរស់នៅដើម្បីញ៉ាំងអោយមនុស្សលោក ស្គាល់ពីតម្លៃជីវិតដែលត្រូវទៅរស់នៅទីកន្លែងអស់កល្បជានិច្ច។ ជីវិតអស់កល្បជានិច្ចមានពីរប្រភេទ មួយគឺនៅជាមួយព្រះជាម្ចាស់ឰដ៏ស្ថានសួគ៌អស់កល្បជានិច្ច មួយទៀត រស់នៅស្ថាននរកដាច់ពីព្រះជាម្ចាស់អស់កល្បជានិច្ច។ យើងត្រូវរស់នៅធ្វើជាគំរូ ដើម្បីអោយមនុស្សលោកចង់ទទួលបានជីវិតអស់កល្បជានិច្ចនៅជាមួយព្រះអម្ចាស់យេស៊ូវ។ ខ្ញុំសូមដណ្តឹងសួរដល់គ្រីស្ទបរិស័ទគ្រប់រូបថា សព្វថ្ងៃ តើលោកអ្នកកំពុងរស់នៅបិទទ្វារ ឬបើកទ្វារស្ថានសួគ៌អោយមនុស្សលោកបានចូលទៅនៅផង?

ខ្ញុំយល់ថា យើងជាមនុស្សគ្រប់រូប រាល់ថ្ងៃពិតជារស់នៅឆ្លុះបញ្ចាំងពីជីវិតប្រភេទនោះ ពោលគឺ បិទ ឬបើកទ្វារស្ថានសួគ៌។

# ជំពូក ៤០

***ផាវចនា*** *បទទំនាយពីព្រះយេស៊ូវ ត្រូវគេធ្វើគុតដោយឆ្កាង*

ជំពូក៤០-៤១ រាប់បញ្ចូលជាប្រភេទបទទំនាយពីព្រះអម្ចាស់យេស៊ូវ។ ទ្រង់យាងមកបំពេញកិច្ចការរបស់ទ្រង់ ដើម្បីមកសង្គ្រោះព្រលឹងមនុស្សលោក។ មិនតែប៉ុណ្ណោះ ជំពូកទាំងពីរខាងលើ មានប្រើយ៉ាងច្រើននៅក្នុងព្រះគម្ពីរសញ្ញាថ្មី។

**ខ្ញុំបានរង់ចាំព្រះយេហូវ៉ា ដោយអំណត់ ទ្រង់ក៏បានផ្អៀងព្រះកាណ៌មកស្តាប់ ហើយទទួលតាមសំរែករបស់ខ្ញុំ (ទំនុកដំកើង៤០:១)។**

គម្ពីរទំនុកដំកើងជំពូក៣៩-៤១ បរិយាយសាច់រឿងស្រដៀងគ្នាយ៉ាងខ្លាំង។ ខ្លះយល់ថា ព្រះបាទដាវីឌបានកត់ត្រាសេចក្តីទាំងនេះ ពេលដែលលោករត់គេចខ្លួនពីបុត្រារបស់ទ្រង់ធ្វើរដ្ឋប្រហារដណ្តើមរាជបល្ល័ង្ក។ ការសន្និដ្ឋាននេះ ត្រឹមត្រូវមួយចំនួនដែរ។ ប៉ុន្តែ បទគម្ពីរនេះ មិនមែនគ្រាន់តែជាទុក្ខលំបាកដែលព្រះបាទដាវីឌរត់គេចពីបុត្រាតែប៉ុណ្ណោះទេ។ បទគម្ពីនេះសម្តែងពីសេចក្តីសរសើរ និងការអរព្រះគុណដល់ព្រះជាម្ចាស់ពីសេក្តីរស់ឡើងវិញ ជោគជ័យ និងហេតុការណ៍ដែលព្រះយេស៊ូវទ្រង់យាង

ត្រឡប់ទៅស្ថានសួគ៌វិញ។ ជំពូកនេះ បរិយាយពីបទទំនាយទាក់ទងពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះយេស៊ូវសុគតមិនមែនជារឿងបរាជ័យទេ ផ្ទុយទៅវិញ ជាការជោគជ័យយ៉ាងត្រចះត្រចង់។ ព្រះបាទដាវីឌបញ្ជាក់យ៉ាងច្បាស់នៅក្នុងខ១ខាងលើថា "ខ្ញុំបានរង់ចាំព្រះយេហូវ៉ា ដោយអំណត់ ទ្រង់ក៏បានផ្អៀងព្រះកាណ៌មកស្តាប់ ហើយទទួលតាមសំរែករបស់ខ្ញុំ"។ សម្រែកនេះ ជាសម្រែករបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់បន្លឺនៅលើឈើឆ្កាង។

> **ទ្រង់បានស្រង់ខ្ញុំចេញពីអន្លង់គួរស្ញើម ឱ្យរួចពីភក់ល្បិត ក៏ដាក់ជើងខ្ញុំលើថ្មដា ព្រមទាំងតាំងជំហានខ្ញុំឱ្យខ្ជាប់ខ្ជួន (ទំនុកដំកើង ៤០:២)។**

សម្រែកដែលព្រះអម្ចាស់យេស៊ូវបន្លឺនៅលើឈើឆ្កាង ជាសម្រែកដ៏ឈឺចាប់។ នៅលើលោកនេះ យើងមិនអាចរកអ្វីមកប្រៀបផ្ទឹមបានទាល់តែសោះ។

> **ទ្រង់បានបណ្តាលឱ្យមានទំនុកថ្មីនៅក្នុងមាត់ខ្ញុំ គឺជាសេចក្តីសរសើរដល់ព្រះនៃយើងខ្ញុំ មនុស្សជាច្រើននឹងឃើញព្រមទាំងមានសេចក្តីកោតខ្លាច ហើយនឹងទុកចិត្តដល់ព្រះយេហូវ៉ាផង (ទំនុកដំកើង៤០:៣)។**

ខខាងលើជាចម្រៀងថ្មី ពោលគឺជាចម្រៀងសម្រាប់អ្នកដែលបានទទួលសេចក្ដីប្រោសលោះ។

"មនុស្សជាច្រើននឹងឃើញ ព្រមទាំងមានសេចក្ដីកោតខ្លាច ហើយនឹងទុកចិត្ដដល់ព្រះយេហូវ៉ាផង"។ តើមនុស្សផងទាំងពួងគេឃើញអ្វី? គេឃើញព្រះអម្ចាស់យេស៊ូវសុគត រួចហើយរស់ឡើងវិញ។

**មានពរហើយ អ្នកណាដែលយកព្រះយេហូវ៉ាជាទីពឹង ឥតយល់ដល់មនុស្សឆ្មើងឆ្មៃ ឬពួកអ្នកដែលបែរទៅឯសេចក្ដីភូតភរឡើយ (ទំនុកដំកើង៤០:៤)។**

ការចុះចូលចំពោះបំណងព្រះហឫទ័យព្រះជាម្ចាស់ រហូតទ្រង់សុគត ជាគំរូសម្រាប់មនុស្សលោកចុះចូលចំពោះព្រះជាម្ចាស់។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទ មិនអោយតម្លៃដល់អ្នកណាអួតខ្លួន ក៏មិនអោយតម្លៃដល់ជនណាដែលនិយាយពាក្យភូតភរចេញពីបបូរមាត់របស់ខ្លួន។

**ឱព្រះយេហូវ៉ាដ៏ជាព្រះនៃទូលបង្គំអើយ ការអស្ចារ្យដែលទ្រង់បានធ្វើ នោះមានច្រើនណាស់ ព្រមទាំងគំនិតដែលទ្រង់នឹកដល់យើងខ្ញុំផង គ្មានអ្នកណាអាចនឹងរៀបរាប់ដោយលំដាប់ពីការទាំងនោះ**

**នៅចំពោះទ្រង់បានឡើយ បើទូលបង្គំនឹងចង់និទានប្រាប់ នោះ មានច្រើនហួសកំណត់នឹងរាប់បាន (ទំនុកដំកើង៤០:៥)។**

ព្រះជាម្ចាស់ សម្តែងព្រះហឫទ័យស្រឡាញ់របស់ទ្រង់ចំពោះមនុស្សលោក ដោយបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ អោយមកទទួលការសុគតនៅលើឈើឆ្កាង។ ផែនដីនេះ ជាពិភពតែមួយគត់ដែលព្រះអម្ចាស់បញ្ជូនព្រះរាជបុត្រារបស់ទ្រង់អោយមកសុគតជំនួសមនុស្សលោក។ ដោយហេតុនេះបានជា "មនុស្សជាច្រើននឹងឃើញ ព្រមទាំងមានសេចក្តីកោតខ្លាច ហើយនឹងទុកចិត្តដល់ព្រះយេហូវ៉ាផង"។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទសុគតនៅលើឈើឆ្កាង ដើម្បីបើកសម្តែងពីសេចក្តីស្រឡាញ់ ព្រះជាម្ចាស់ប្រទានមកដល់មនុស្សលោក។

ខគម្ពីរខាងក្រោមនេះ ត្រូវយកមកប្រើយោងក្នុងគម្ពីរហេព្រើរ:

**[៦]ឯយញ្ញបូជា ហើយនឹងដង្វាយ នោះទ្រង់មិនសព្វព្រះហឫទ័យទេ
ទ្រង់បានបើកត្រចៀកឱ្យទូលបង្គំស្តាប់តាម ទ្រង់មិនចង់បាន
ដង្វាយដុត ឬយញ្ញបូជាលោះបាបនោះទេ [៧]បានជាទូលបង្គំទូលថា
មើល ទូលបង្គំមកហើយ សេចក្តីនេះបានកត់ទុកពីទូលបង្គំ នៅ
ក្នុងគម្ពីរហើយ [៨]គឺថា ឱព្រះនៃទូលបង្គំអើយ ទូលបង្គំមានសេចក្តី
អំណរ នឹងធ្វើតាមព្រះហឫទ័យទ្រង់ អើ ក្រិត្យវិន័យរបស់ទ្រង់ក៏**

**នៅក្នុងចិត្តទូលបង្គំ ទូលបង្គំបានប្រកាសដំណឹងល្អ ពីសេចក្តីសុចរិតនៅក្នុងជំនុំធំ មើល ឱព្រះយេហូវ៉ាអើយ ទ្រង់ជ្រាបហើយថា ទូលបង្គំនឹងមិនទប់មាត់ឡើយ (ទំនុកដំកើង៤០:៦-៩)។**

អត្ថបទខាងលើ សម្តែងពីភាពទ័លច្រកនៃមនុស្សលោកគ្រប់រូប។ គម្ពីរហេព្រើរ១០:៥ សម្តែងថា "ព្រះអង្គមិនចង់បានយញ្ញបូជា នឹងដង្វាយទេ តែទ្រង់បានរៀបចំរូបកាយឱ្យទូលបង្គំវិញ"។ នៅក្នុងខនេះយើងឃើញថា "ទ្រង់បានរៀបចំរូបកាយអោយទូលបង្គំវិញ"។ ចំណែកគម្ពីរទំនុកដំកើងជំពូក៤០:៦ ទ្រង់មានបន្ទូលថា "ទ្រង់បានបើកត្រចៀកឱ្យទូលបង្គំស្តាប់តាម"។ អ្នកខ្លះយល់ថា អ្នកចម្លងខគម្ពីរចេញពីគម្ពីរទំនុកដំកើង៤០:៦ មកដាក់ក្នុងគម្ពីរហេព្រើរ១០:៥ ធ្វើដោយច្រឡំ។ រឿងនេះមិនមែនជាការច្រឡំទេ។ ខ្ញុំសូមពន្យល់ដូចខាងក្រោមនេះ។

ព្រះវិញ្ញាណបរិសុទ្ធ ណែនាំអោយហោរារបស់ទ្រង់សរសេរគម្ពីរទំនុកដំកើងជំពូក៤០ និងហេព្រើរជំពូក១០។ ព្រះវិញ្ញាណបរិសុទ្ធមានមូលហេតុច្បាស់លាស់ បានជាព្រះអង្គបង្គាប់អោយពួកហោរាសរសេរបែបនោះ។ គម្ពីរនិក្ខមនំជំពូក២១ សម្តែងពីបាវប្រុសដែលបម្រើចៅហ្វាយណាម្នាក់។ ពេលបាវបម្រើមានសិទ្ធិអាចដោះបំណុលខ្លួនឯងបាន តែបែរជាសូមដល់ចៅហ្វាយនៅតទៅទៀត ដោយយល់ដល់ប្រពន្ធហើយនិងកូនរបស់ខ្លួន ចៅហ្វាយត្រូវយកបាវនោះទៅចោះត្រចៀកនៅមាត់ទ្វារ។ ការចោះត្រចៀកមានន័យថា ទទួលយកធ្វើជាឈ្នួលជានិច្ចនៅក្នុងផ្ទះរបស់ចៅហ្វាយតរៀងទៅ

(និក្ខមនំ២១:៦)។ ការចោះត្រចៀកមានន័យថា បើកត្រចៀកដើម្បីអោយយល់ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ពេលព្រះអម្ចាស់យេស៊ូវយាងមកគង់លើផែនដី គេយករូបកាយរបស់ព្រះអង្គទៅចោះដោយដែកគោលនៅលើឈើឆ្កាង។ ទ្រង់សុគតជំនួសមនុស្សមានបាប។ ទ្រង់មិនមែនគ្រាន់តែយាងមកធ្វើតាមព្រះហឫទ័យបំណងរបស់ព្រះជាម្ចាស់ ដោយគ្រាន់តែអោយគេចោះត្រចៀកទ្រង់ប៉ុណ្ណោះទេ។ ព្រះអង្គអោយគេចោះរូបកាយរបស់ព្រះអង្គថែមទៀតផង។ ព្រះអង្គបំពេញតួនាទីនេះ ដើម្បីកុំអោយយើងជាអ្នកជឿលព្រះអង្គចាំបាច់អោយគេចោះរូបកាយយើងដោយដែកគោល។ យើងអាចទៅនៅជាមួយព្រះអង្គជារូបកាយពេញលក្ខណៈ ព្រោះព្រះអង្គទទួលស្នាមរបួសជំនួសយើងរួចហើយ។

# ជំពូក ៤១

***ចាចនា*** *បទទំនាយពីយូដាសក្បត់ព្រះយេស៊ូវ*

ព្រះបាទដាវីដបានកត់ត្រាទុកគម្ពីរទំនុកដំកើងនេះ ពេលដែលសង្ឃមួយអង្គជាមិត្តក្បត់លោក។ សង្ឃអង្គនេះបានចូលដៃជាមួយនឹងអាប់សាឡំម ធ្វើរដ្ឋប្រហារដណ្ដើមរាជបល្ល័ង្កពីដាវីឌ។ រឿងនេះ មានបរិយាយក្នុងគម្ពីរ២សាំយ៉ូអែលជំពូក១៧។ សង្ឃអ័ហ៊ីថូផែល ជាតួអង្គយូដាសអ៊ីស្ការីយ៉ុត ក្បត់ព្រះយេស៊ូវ។

គម្ពីរទំនុកដំកើងជំពូក៤១ ចាប់ផ្ដើមដោយបទប្រសិទ្ធពរ។

> **មានពរហើយ អ្នកណាដែលមានអធ្យាស្រ័យ ដល់ពួកមនុស្សក្រីក្រ ព្រះយេហូវ៉ាទ្រង់នឹងជួយអ្នកនោះ ឱ្យរួចក្នុងថ្ងៃអាក្រក់ (ទំនុកដំកើង៤១:១)។**

ជំពូកគម្ពីរនេះ បញ្ចប់ដោយបទប្រទានពរដែរ។ ពាក្យថា មានពរប្រែថា រីករាយ។

**អើ ទាំងមិត្រសំឡាញ់ស្និទ្ធស្នាលរបស់ទូលបង្គំ ជាអ្នកដែលទូលបង្គំបានទុកចិត្ត ហើយក៏បានបរិភោគបាយរបស់ទូលបង្គំផង នោះបានលើកកែងជើងចង់ជាន់ឈ្លីទូលបង្គំដែរ (ទំនុកដំកើង៤១:៩)។**

ព្រះអម្ចាស់យេស៊ូវគ្រីស្ទ សូត្រខគម្ពីរម្តងទៀត ពេលដែលទ្រង់មានបន្ទូលពីលោកយូដាសអ៊ីស្ការីយ៉ុត។ ព្រះអង្គមានបន្ទូលថា "អ្នកដែលបរិភោគនំបុ័ង ជាមួយនឹងទូលបង្គំ នោះបានលើកកែងជើង ទាស់នឹងទូលបង្គំវិញ" (យ៉ូហាន១៣:១៨)។ ខគម្ពីរនេះសម្រេចឡើងនៅពេលដែលយូដាសអ៊ីស្ការីយ៉ុតក្បត់ទ្រង់។ នៅក្នុងគម្ពីរកិច្ចការ ១:១៦ សាវ័កពេត្រុសសម្តែងថា "បងប្អូនរាល់គ្នាអើយ បទគម្ពីរដែលព្រះវិញ្ញាណបរិសុទ្ធបានទាយ ដោយសារព្រះឱស្ឋហ្លួងដាវីឌ ពីដំណើរយូដាស ជាអ្នកដែលនាំគេទៅចាប់ព្រះយេស៊ូវ បទនោះត្រូវតែបានសំរេច"។ មិនតែប៉ុណ្ណោះ មានសេចក្តីសរសេរបន្ថែមខាងក្រោមនេះថា:

**តែ ឱព្រះយេហូវ៉ាអើយ សូមទ្រង់អាណិត មេត្តាលើកទូលបង្គំឡើងវិញ ដើម្បីឲ្យទូលបង្គំបានសងតបដល់គេ (ទំនុកដំកើង ៤១:១០)។**

ខនេះ សម្តែងពីសេចក្តីរស់ឡើងវិញនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ "ឱព្រះ

យេហូវ៉ាអើយ សូមទ្រង់អាណិតមេត្តាលើកទូលបង្គំឡើងវិញ ដើម្បីឱ្យទូលបង្គំបានសងតបដល់គេ"។ ព្រះអម្ចាស់យេស៊ូវសុគត ហើយរស់ពីសុគតឡើងវិញ។ ខ្ញុំចង់អោយលោកអ្នកយល់យ៉ាងច្បាស់ពីចំណុចនេះ។ សេចក្តីសុគតរបស់ព្រះអម្ចាស់យេស៊ូវ មិនអាចផ្តល់សេចក្តីសង្គ្រោះដល់យើងបានទេ។ សេចក្តីសុគតបូកនឹងការរស់ឡើងវិញនៃព្រះអម្ចាស់យេស៊ូវ ទើបផ្តល់សេចក្តីសង្គ្រោះដល់មនុស្សមានបាប។ សាវ័កប៉ុលបញ្ជាក់ក្នុងគម្ពីរ ១កូរិនថូស១៥:៣-៤ថា "ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នករាល់គ្នា តាមសេចក្តីដែលខ្ញុំបានទទួលដែរ គឺថាព្រះគ្រីស្ទបានសុគតដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ ហើយថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ"។ បើគ្មានការរស់ឡើងវិញនៃព្រះអម្ចាស់យេស៊ូវទេ ដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវក៏គ្មានដែរ។ នៅពេលព្រះអម្ចាស់យេស៊ូវយាងមកបំពេញកិច្ចការងាររបស់ទ្រង់នៅលើផែនដីនេះ មានមនុស្សលោកច្រើនណាស់ចោទទ្រង់ថា ព្រះអង្គជាអ្នកនេះ ឬជាអ្នកនោះ។ គេឆ្ងល់ថា "តើព្រះយេស៊ូវជាអង្គណា?" ដោយសារមូលហេតុនោះ ព្រះអម្ចាស់យេស៊ូវដណ្តឹងសួរដល់ពួកសាវ័ករបស់ទ្រង់ថា "...តើមនុស្សទាំងឡាយ គេថាកូនមនុស្សជាអ្នកណា?" ទ្រង់មានបន្ទូលសួរថា "ចុះឯអ្នករាល់គ្នាវិញតើថាខ្ញុំជាអ្នកណា?" ស៊ីម៉ូន-ពេត្រុសទូលឆ្លើយថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់"។ ចំពោះលោកអ្នកផ្ទាល់វិញ តើយល់ថា ព្រះអង្គជានរណា? មនុស្សសម័យថ្មីនេះគេយល់ថា ព្រះអម្ចាស់យេស៊ូវគ្រាន់តែជាគ្រូបង្ហាត់បង្រៀនសីលធម៌យ៉ាងខ្ពង់ខ្ពស់មួយរូបតែប៉ុណ្ណោះ។ លោកប្រធានាធិបតីថូម៉ាសហិហ្វហ្វ័រសិន មិនជឿ

ថាព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញទេ។ រដ្ឋបុរសរូបនេះ គោរពព្រះអម្ចាស់យេស៊ូវដោយគ្រាន់តែជឿថា ព្រះអម្ចាស់យេស៊ូវជាបរមគ្រូមួយរូប ក្នុងចំណោមគ្រូដទៃៗទៀត។ បើគេមិនជឿថា ព្រះអម្ចាស់យេស៊ូវរស់ឡើងវិញ ដំណឹងល្អរបស់ព្រះអង្គក៏មិនមានដែរ។ ព្រះអម្ចាស់យេស៊ូវពិតជារស់ឡើងវិញមែន។ គេបើកផ្នូរដើម្បីបញ្ជាក់ថា ព្រះអង្គមិននៅសុគតក្នុងផ្នូរនោះទៀតទេ។

ព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ។ ដោយសារមូលហេតុនោះ បានជាយើងអាចប្រកាសជាឱឡារិកថា:

> **សូមលើកសរសើរដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ចាប់តាំងពីអតីត ទៅដល់អនាគត អស់កល្បជានិច្ច អាម៉ែន ហើយអាម៉ែន (ទំនុកដំកើង៤១:១៣)។**

យើងឃើញជំពូកនេះបញ្ចប់ដោយឃ្លាថា "អស់កល្បជានិច្ច អាម៉ែន ហើយអាម៉ែន"។ ការប្រើពាក្យ "អាម៉ែន" ពីរដង មានន័យថា សេចក្ដីសង្គ្រោះដែលព្រះអម្ចាស់ប្រទានមកដល់មនុស្សលោកតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ បានធ្វើរួចជាស្រេចអស់ហើយ។ ព្រះគ្រីស្ទយាងមកសុគត រស់ឡើងវិញ រួចហើយទ្រង់យាងឡើងទៅស្ថានសួគ៌។ ក្នុងវិនាទីនេះ ព្រះអង្គគង់នៅទីខាងស្ដាំនៃបល្ល័ង្ករបស់ព្រះជាម្ចាស់។ ព្រះអម្ចាស់យេស៊ូវ បំពេញកិច្ចការសង្គ្រោះដល់មនុស្សលោកស្រេចចប់សព្វគ្រប់ហើយ។

លោកអ្នកមិនចាំបាច់ធ្វើអ្វីបន្ថែមទៀតទេ។ ផ្ទុយទៅវិញ លោកអ្នកចាំបាច់ត្រូវទទួលជឿថា ព្រះអម្ចាស់យេស៊ូវសុគតហើយរស់ឡើងវិញជំនួសអំពើបាបរបស់លោកអ្នក។ ជំនឿនោះ នាំអោយលោកអ្នកបានទទួលបាននូវសេចក្តីសង្គ្រោះ។ ម្យ៉ាងវិញទៀត ដំណឹងល្អដែលមិននិយាយពីព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ មិនមែនជាដំណឹងល្អទាល់តែសោះ។

គម្ពីរទំនុកដំកើងពីជំពូក១-៤១ រាប់ថាជាគម្ពីរលោកុប្បត្តិសម្រាប់គម្ពីរទំនុកដំកើង។ គម្ពីរលោកុប្បត្តិគ្រាន់តែបញ្ជាក់ពីបទទំនាយខ្លះៗ ទាក់ទងនឹងព្រះអម្ចាស់យេស៊ូវដែលបំពេញតួនាទីជាអង្គសង្គ្រោះ។ ចំណែកគម្ពីរទំនុកដំកើងមហាវគ្គទីមួយគឺពីជំពូក១-៤១ សម្តែងយ៉ាងពិស្តារពីព្រះអម្ចាស់យេស៊ូវ ដែលទ្រង់យាងមកបំពេញតួនាទីធ្វើជាអង្គសង្គ្រោះរបស់មនុស្សលោក។ ហេតុការណ៍ដែលកើតឡើងនៅក្នុងគម្ពីរលោកុប្បត្តិ គ្រាន់តែជាថ្នាលសម្រាប់សាបព្ជជ។ ចំណែកគម្ពីរទំនុកដំកើងជំពូក១-៤១ ជាលានសម្រាប់យកព្ជជមកស្ទូង ដើម្បីបង្កើតជាផលផ្លែ។ គម្ពីរលោកុប្បត្តិចប់ដោយក្តារមឈូសនៅស្រុកអេស៊ីព្ទ គម្ពីរទំនុកដំកើងជំពូក១-៤១ បញ្ចប់ដោយសិរីល្អរុងរឿងនៃការរស់ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

យើងស្វែះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"